ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................

*រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ការផ្ទេរបុរាណវត្ថុ និងវត្ថុសិល្បៈ
## ពីសារមន្ទីរជាតិកម្ពុជា ទៅកាន់សារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីឦសានវរ្ម័ន
## រវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងធនាគារជាតិនៃកម្ពុជា

នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ៤:០០រសៀល ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងធនាគារជាតិនៃកម្ពុជា បានរៀបចំពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពី ការផ្ទេរបុរាណវត្ថុ និងវត្ថុសិល្បៈមួយចំនួន ពីសារមន្ទីរជាតិកម្ពុជា ទៅកាន់សារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះស្រីឦសានវរ្ម័ន ហៅកាត់ថា "សារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងលោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ត្រូវបានប្រារព្ធឡើងក្រោមបរិយាកាសប្រកបដោយកិច្ចសហប្រតិបត្តិការយ៉ាងល្អ រវាងធនាគារជាតិនៃកម្ពុជា និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្នុងកិច្ចដំណើរការរៀបចំកសាងសារមន្ទីរមួយ ដើម្បីឱ្យសាធារណជនជាតិនិងអន្តរជាតិ បានចូលទស្សនា និងសិក្សាស្វែងយល់ពីប្រវត្តិរូបិយវត្ថុនៅកម្ពុជា សារៈសំខាន់នៃរូបិយវត្ថុ ប្រព័ន្ធរូបិយវត្ថុ និងតួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិកន្លងមក ក៏ដូចជាធ្វើជាមជ្ឈមណ្ឌលឯកសាររូបិយវត្ថុមួយសម្រាប់សាធារណជនទូទៅគ្រប់មជ្ឈដ្ឋាន ។

បុរាណវត្ថុ និងវត្ថុសិល្បៈ ដែលត្រូវបានផ្ទេរក្នុងពេលនេះមានចំនួន ៦៧មុខ រួមមាន កាស ប្រាក់ផ្លែពន្លាក ដុំលោហៈ ដែកទាមថ្មប្រាសាទ កំសៀវទឹកប្រើប្រាស់ក្នុងសម័យបុរាណ ធនាគារជាតិនៃកម្ពុជានឹងរក្សាទុកវត្ថុដ៏មានតម្លៃឥតគណនានេះ ជាសម្បត្តិបេតិកភណ្ឌរបស់ជាតិ ។ ជាមួយគ្នានេះ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នឹងបន្តគាំទ្រ និងផ្តល់កិច្ចសហប្រតិបត្តិការល្អដល់ធនាគារជាតិនៃកម្ពុជា ដើម្បីរៀបចំសារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុនេះឱ្យកាន់តែមានភាពប្រចក្សទៅនឹងដំណាក់កាលព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ប្រវត្តិរូបិយវត្ថុ និងសេដ្ឋកិច្ចកម្ពុជា ។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh